# គម្ពីរសញ្ញាចាស់


កំពុងអានអីហ្នឹង?
កណ្ឌគម្ពីរ និក្ខមនំ
ម៉េចបានត្រីស្នូបរិស័ទអានទាំងគម្ពីរ
សញ្ញាចាស់ដែរអញ្ចឹង? ព្រះនៅគ្រាសញ្ញាចាស់
កាចណាស់ទាំងចូលចិត្តដាក់ទោស
ហើយតឹងតែងមែនទែន។
តែក្រោយមកព្រះយេស៊ូវបានយាងមករួចក៏
ធ្វើគ្រប់យ៉ាងដោយក្ដីស្រឡាញ់ សន្តិភាព អត់ទោស
មានសុខសាន្ត ហើយទទួលយកយើងទៀតផង។
ខ្ញុំពិតជាស្រឡាញ់ព្រះគម្ពីរសញ្ញាថ្មីខ្លាំងណាស់។


តាមពិត អ្នកគួរអានគម្ពីរសញ្ញាចាស់ឲ្យលម្អិតជាងមុន។ «ព្រះនៅគ្រាសញ្ញាចាស់» និង «ព្រះយេស៊ូវដែលបានយាងមក» គឺជាព្រះដូចគ្នា ព្រះមិនបានប្រែប្រួលទេសម្លាញ់។
ប៉ុន្តែក្នុងគម្ពីរសញ្ញាចាស់ យើងឃើញថាព្រះជាម្ចាស់សម្លាប់មនុស្ស និងធ្វើអ្វីៗផ្សេងៗ! តែក្នុងគម្ពីរសញ្ញាថ្មីវិញ យើងឃើញថាព្រះយេស៊ូវផ្អែមល្ហុយដូចដូងដុតអញ្ចឹង... ទ្រង់ថែមទាំងអនុញ្ញាតឲ្យក្មេងៗ មកអង្គុយលើភ្លៅទៀតផង!
ព្រះជាម្ចាស់គឺជាព្រះដែលមានពេញដោយក្ដីស្រឡាញ់ តែទ្រង់ក៏ជាព្រះដ៏យុត្តិធម៌ដែរ។ ព្រះជាម្ចាស់មានក្ដីមេត្តាករុណាតែព្រះអង្គក៏ជាភ្លើងដែលឆេះបន្សុសដែរណា។ នេះគឺជាការពិតទាំងក្នុងសញ្ញាចាស់ និងសញ្ញាថ្មី មានបញ្ជាក់យ៉ាងច្បាស់។
ដូច្នេះ តើអ្នកគិតថាព្រះយេស៊ូវគង់នៅឯណាមុនដែលទ្រង់យាងមកយកកំណើតជាមនុស្ស?តើអ្នកគិតថាទ្រង់គង់លើពពកហើយអង្គុយរៀបរូបផ្គុំឬអង្គុយគូសវាស់ពាក្យ ឬក៏ធ្វើអ្វីផ្សេងទៀតឬ?
កុំភ្លេចថាយើងកំពុងតែជជែកគ្នាអំពីព្រះយេស៊ូវណា។ ទ្រង់ជាបុគ្គលទីពីរនៃព្រះត្រៃឯកដ៏គង់នៅអស់កល្បជានិច្ច។ ទ្រង់ជាបុគ្គលដែល «មិនប្រែប្រួលទោះម្សិលមិញថ្ងៃនេះនិងរហូតអស់កល្ប»។ ព្រះរាជបុត្រាគឺជាព្រះ។ ព្រះ។ ព្រះរាជបុត្រា។ ព្រះមិនចេះប្រែប្រួលឡើយ។ តើអ្នកយល់អំពីអ្វីដែលខ្ញុំកំពុងនិយាយទេ?
ចាំតិច...អ្នកកំពុងតែថា...
បាទ...ត្រូវហើយ


ការជំនុំជម្រះ...សង្គ្រាម...
និងគ្រោះកាច...មែនឬ?
ត្រូវហើយ
ដូចក្រុងសូដុំមនិង
ក្រុងកូម៉ូរ៉ា???
ព្រះជាម្ចាស់គឺជាព្រះ ៖ ព្រះវរបិតា ព្រះរាជបុត្រា
និងព្រះវិញ្ញាណបរិសុទ្ធ។ ចូរចាំថា ព្រះរាជបុត្រាក៏
ជាព្រះដែរ។ ព្រះយេស៊ូវគឺជាព្រះ មិនថាពេលនេះ
ឬក៏នៅគ្រាសញ្ញាចាស់នោះទេ។ ព្រះយេស៊ូវជាព្រះ
តាំងពីដរាបមកម្ល៉េះ។


តើអ្នកដឹងពីការទាំងនេះដោយរបៀបណា?
ព្រះយេស៊ូវដែលអ្នកគិតថាជា «ដូងដុត» ទ្រង់បានមាន
បន្ទូលច្រើនណាស់ពីការនេះ នៅក្នុងគម្ពីរសញ្ញាថ្មី
ដែលអ្នកស្រឡាញ់ហ្នឹងឯង។
អ្វីដែលអ្នកនិយាយកំពុងបំផ្លាញគំនិតដែលខ្ញុំមាន
អំពីព្រះយេស៊ូវទាំងស្រុងហើយ។
ព្រះគម្ពីរពូកែខាងការនេះណាស់។
Adam4d.com

តើនេះជាព្រះយេស៊ូវដែលលោកអ្នកកំពុងថ្វាយបង្គំ?

ដ្បិតព្រះយេស៊ូវគ្រីស្ទទ្រង់នៅតែដដែល គឺពីថ្ងៃម្សិល ថ្ងៃនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ (ហេព្រើរ ១៣:៨)។

ដ្បិតព្រះនៃយើងរាល់គ្នាទ្រង់ជាភ្លើងដែលឆេះបន្សុស (ហេព្រើរ ១២:២៩) ។

ដ្បិតព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ជាព្រះដ៏មានសេចក្តីមេត្តាករុណា ទ្រង់មិនខាននឹងប្រោសឯងទេ ក៏មិនបំផ្លាញឯងឬភ្លេចសេចក្តីសញ្ញា ដែលទ្រង់បានស្បថនឹងពួកឰយុកោឯងឡើយ (ចោទិយកថា ៤:៣១)។

គឺព្រះយេស៊ូវគ្រីស្ទនេះហើយ ដែលយាងមកដោយទឹក ហើយនឹងឈាម មិនមែនដោយទឹកតែប៉ុណ្ណោះ គឺទាំងទឹកទាំងឈាមផង គឺជាព្រះវិញ្ញាណដែលធ្វើបន្ទាល់ ដ្បិតព្រះវិញ្ញាណទ្រង់ជាសេចក្តីពិត មានសាក្សី៣អង្គ ដែលធ្វើបន្ទាល់នៅស្ថានសួគ៌ គឺជាព្រះវរបិតា១ ព្រះបន្ទូល១ នឹងព្រះវិញ្ញាណបរិសុទ្ធ១ តែទាំង៣អង្គនេះរួមមកតែ១ទេ
ហើយមាន៣មុខទៀត ដែលធ្វើបន្ទាល់នៅផែនដីដែរ គឺជាព្រះវិញ្ញាណ១ ទឹក១ នឹងឈាម១ ទាំង៣នេះក៏ត្រូវគ្នាដែរ បើសិនជាយើងបានទទួលសេចក្តីបន្ទាល់របស់មនុស្សទៅហើយ នោះសេចក្តីបន្ទាល់របស់ព្រះ ក៏ប្រសើរជាងទៅទៀត ដ្បិតសេចក្តីបន្ទាល់របស់ព្រះ គឺជាសេចក្តីដែលទ្រង់ថ្លែងប្រាប់ ពីព្រះរាជបុត្រានៃទ្រង់ អ្នកណាដែលជឿដល់ព្រះរាជបុត្រានៃព្រះ នោះមានសេចក្តីបន្ទាល់ នៅក្នុងខ្លួនហើយ តែអ្នកណាដែលមិនជឿដល់ព្រះសោះ នោះឈ្មោះថា បានធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ ពីព្រោះមិនបានជឿដល់សេចក្តីបន្ទាល់ ដែលទ្រង់បានធ្វើពីដំណើរព្រះរាជបុត្រានៃទ្រង់ នេះហើយជាសេចក្តីបន្ទាល់នោះ គឺថា ព្រះទ្រង់បានប្រទានជីវិតដ៏នៅអស់កល្បជានិច្ចមកយើងរាល់គ្នា ហើយជីវិតនោះ គឺនៅក្នុងព្រះរាជបុត្រានៃទ្រង់ ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ (១យ៉ូហាន ៥:៦-១២)

ដកស្រង់ចេញពី adam4d.com ដោយការអនុញ្ញាត។

បកប្រែដោយ៖ លោក ឈាង បូរ៉ា និង លោក ជួប ប៊ុនហាក់
រចនាអត្ថបទភាសាខ្មែរ៖ លោក ជួប ប៊ុនហាក់ និងលោក ទេព រ៉ូ